ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែងនេសាទ
# សហគមន៍នេសាទតំបន់ឆ្នេរសមុទ្រឃុំជ្រោយស្វាយ
# រយៈពេល ៣ ឆ្នាំ
# (២០១៧ - ២០១៩)

| | |
|---|---|
| ឈ្មោះសហគមន៍នេសាទ: | តំបន់ឆ្នេរសមុទ្រឃុំជ្រោយស្វាយ |
| ភូមិ: | ជ្រោយស្វាយលិច |
| ឃុំ: | ជ្រោយស្វាយ |
| ស្រុក: | ស្រែអំបិល |
| ខេត្ត: | កោះកុង |

## មាតិកា


១.ស្ថានភាពទូទៅ.......3
២.អំពីប្រជាសាស្ត្រ និង សេដ្ឋកិច្ចសង្គម.......3
ក-ប្រជាពលរដ្ឋ.......3
ខ.មុខរបរ.......3
៣.កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍.......4
ក-ទីតាំង.......4
ខ-ដែននេសាទ.......4
គ-តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស.......4
ឃ-ធនធានជលផល.......5
៤.ការធ្វើនេសាទ.......5
ក-អ្នកនេសាទ.......5
ខ-ឧបករណ៍នេសាទ.......5
គ-ប៉ាន់ប្រមាណ ផលនេសាទចាប់បានប្រចាំឆ្នាំ.......6
៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍.......6
ក-ទស្សនៈវិស័យ.......6
ខ-គោលបំណង.......6
គ-ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍.......7
គ-១-ផែនការប្រើប្រាស់ឧបករណ៍នេសាទ:.......7
គ-២-ផែនការកែលម្អដែននេសាទ.......7
គ-៣-ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស.......8
គ-៤-ផែនការគ្រប់គ្រងព្រៃលិចទឹក.......9
គ-៥-ផែនការអភិវឌ្ឍន៍វារីវប្បកម្ម.......9
គ-៦-ផែនការថវិកាទ្រទ្រង់សំរាប់អភិវឌ្ឍសហគមន៍.......9
គ-៧-ផែនការផ្សេងៗទៀត.......10
ឃ- យុទ្ធសាស្ត្រ.......10

# ផែនការគ្រប់គ្រង
# តំបន់នេសាទសហគមន៍

## ១.ស្ថានភាពទូទៅ

សហគមន៍នេសាទតំបន់ឆ្នេរសមុទ្រឃុំជ្រោយស្វាយ ត្រូវបានបង្កើតឡើងដោយមហាសន្និបាតកំណើតដំបូង នៅថ្ងៃទី ២៩ ខែ មេសា ឆ្នាំ២០០៥ ។សហគមន៍នេសាទតំបន់ឆ្នេរសមុទ្រឃុំជ្រោយស្វាយ មានទីតាំងស្ថិតនៅក្នុងភូមិជ្រោយស្វាយលិច ឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង ដែលមានសមាជិកសរុបចំនួន ១,៩២៦ នាក់ ស្រីចំនួន ៩៦០ នាក់ និងមានគណៈកម្មការចំនួន១៨ នាក់ ស្រីចំនួន ៤នាក់។ ក្នុងនោះចំនួនគ្រួសារសរុប មានចំនួន ៤៣១ គ្រួសារ។

កន្លងមកសហគមន៍នេសាទនេះបានដំណើរការសកម្មភាពសំខាន់ៗរបស់ខ្លួន រួមមានៈ ការចុះល្បាតជាប្រចាំ ដាំកូនពោងកាង ផ្សព្វផ្សាយពីច្បាប់ជលផល គៀងគរប្រជានេសាទអោយចូលរួមការងារអភិវឌ្ឍន៍សហគមន៍ ទប់ស្កាត់បទល្មើស អភិរក្សកន្លែងជំរកត្រីមេពូជ ដាក់ពោងសប្បនិមិត្ត ៣៥ ប្រអប់ បោះបង្គោលព្រំចំនួន ១៦ ដើម លើផ្ទៃទឹក ៤៣ហិកតា។

## ២.អំពីប្រជាសាស្ត្រ និង សេដ្ឋកិច្ចសង្គម

### ក-ប្រជាពលរដ្ឋ

- ចំនួនប្រជាពលរដ្ឋសរុបក្នុងសហគមន៍នេសាទមាន ៥,០១១ នាក់ ប្រុស ២,៥៧១នាក់ ស្រី ២,៤៤០នាក់ក្នុងនោះមានជនជាតិខ្មែរចំនួន ៥,០១១ នាក់ ខ្មែរឥស្លាមចំនួន ០០នាក់ អាណិកជនវៀតណាមចំនួន០០នាក់។
- ចំនួនស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន ១៥៨ នាក់
- ចំនួនជនពិការក្នុងសហគមន៍នេសាទមាន ២៥ នាក់ ស្រី ១០ នាក់
- ចំនួនចាស់ជរាក្នុងសហគមន៍នេសាទមាន ៥០ នាក់ ស្រី ៣៥ នាក់
- ចំនួនកុមារកំព្រាក្នុងសហគមន៍នេសាទមាន ២៥ នាក់ ស្រី ១៨ នាក់
- ចំនួនអ្នកមានជំងឺរ៉ាំរ៉ៃក្នុងសហគមន៍នេសាទមាន ៤៣ នាក់ ស្រី ២៣ នាក់
- ប្រជាពលរដ្ឋក្នុងសហគមន៍ជាអ្នកកាន់សាសនាព្រះពុទ្ធ ១០០ %។
- ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរមានចំនួន ១,៤៨៥នាក់ ស្រី ៧២៤ នាក់ កំរិតថ្នាក់បឋមសិក្សាចំនួន ៣៤៦ នាក់ ស្រី ១៩០ នាក់ កំរិតមធ្យមសិក្សាមានចំនួន ៩០ នាក់ ស្រី ៤៥ នាក់ និងកំរិតថ្នាក់ឧត្តមសិក្សាមានចំនួន ៥ នាក់ ស្រី ១នាក់

### ខ.មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមានៈ

- ធ្វើនេសាទចំនួន ៤៣១ គ្រួសារ
- ធ្វើស្រែចំនួន ៦០០ គ្រួសារ ទំហំ ៥៦០ ហិកតា
- ដាំបន្លែចំនួន ៤០ គ្រួសារ ទំហំ ៣ ហិកតា
- ជាងផ្ទះចំនួន ៣៣ គ្រួសារ

- ធ្វើចំការចំនួន ១៥ គ្រួសារ ទំហំ ១០០ ហិកតា
- លក់ដូរមានចំនួន ៥៨ គ្រួសារ
- ជាងកាត់សក់ ១គ្រួសារ
- ជាងម៉ូតូ ៥ គ្រួសារ

## ៣.កន្លែងនេសាទសហគមន៍ និងធនធានជលផលដែលមាននៅក្នុងកន្លែងនេសាទសហគមន៍

### ក-ទីតាំង

កន្លែងនេសាទសហគមន៍នេសាទតំបន់ឆ្នេរសមុទ្រឃុំជ្រោយស្វាយ ជាកន្លែងដែននេសាទតំបន់ឆ្នេរសមុទ្រ។

កន្លែងនេសាទសហគមន៍នេសាទតំបន់ឆ្នេរសមុទ្រឃុំជ្រោយស្វាយ មានទំហំ ១៣,៤៤៣ ហិកតានិងមានកំណត់និយាមកា ដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង។

មានព្រំប្រទល់:

- ខាងជើងទល់នឹង: ព្រែកស្រែអំបិល ជាប់សហគមន៍ឆ្នេរសមុទ្រកោះខ្យង
- ខាងត្បូងទល់នឹង: ព្រែកចំរុះ និង សហគមន៍នេសាទកែវផុស
- ខាងកើតទល់នឹង: ឆ្នេរសមុទ្រ និង សហគមន៍ការពារធនធានធម្មជាតិ
- ខាងលិចទល់នឹង: ឆកកំពង់សោម

### ខ-ដែននេសាទ

កន្លែងនេសាទសហគមន៍តំបន់ឆ្នេរសមុទ្រឃុំជ្រោយស្វាយ។មាន ព្រែកចំនួន ៨ ត្រពាំងចំនួន ១១ ។

- ត្រពាំងឈ្មោះ អណ្តូងថ្ម ទំហំ ២ហិកតា នេសាទពីខែ មករា ដល់ខែ ធ្នូ
- ត្រពាំងឈ្មោះ ជ្រោយស្វាយ ទំហំ ២ហិកតា នេសាទពីខែ មករា ដល់ខែ ឧសភា
- ត្រពាំងឈ្មោះ អកយំ ទំហំ ៦ អា នេសាទពីខែ មករា ដល់ខែ ឧសភា
- ត្រពាំងឈ្មោះ រោងលោក ទំហំ ៥ អា នេសាទពីខែ មករា ដល់ខែ ឧសភា
- ត្រពាំងឈ្មោះ ធ្វៃក ទំហំ ៨ អា នេសាទពីខែ មករា ដល់ខែ ឧសភា
- ត្រពាំងឈ្មោះ អណ្តូង ទំហំ ១ហិកតា នេសាទពីខែ មករា ដល់ខែ ធ្នូ
- ត្រពាំងឈ្មោះ ព្រីស ទំហំ ៦ហិកតា នេសាទពីខែ មករា ដល់ខែ ធ្នូ
- ត្រពាំងឈ្មោះ ត្បាល់ ទំហំ ២ហិកតា នេសាទពីខែ មករា ដល់ខែ ឧសភា
- ត្រពាំងឈ្មោះ ចំរុះ ទំហំ ១,៥ហិកតា នេសាទពីខែ មករា ដល់ខែ ធ្នូ
- ត្រពាំងឈ្មោះ ចុងទូល ទំហំ ៥អា នេសាទពីខែ មករា ដល់ខែ ឧសភា
- ត្រពាំងឈ្មោះ បឹងធំ ទំហំ ២,៥ហិកតា នេសាទពីខែ មករា ដល់ខែ ធ្នូ
- ព្រៃឈ្មោះ ចំរុះ ប្រវែង ទទឹង ២០ម៉ែត បណ្តោយ ២៥០០០ម៉ែត្រ។

### គ-តំបន់ដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

- អភិរក្សឈ្មោះ ថ្មធំ មានទំហំ ១១ ហិកតា

- អភិរក្សឈ្មោះ ពយទង់ មានទំហំ ២១ ហិកតា
- អភិរក្សឈ្មោះ ថ្មចំរុះ មានទំហំ ២០ ហិកតា
- អភិរក្សឈ្មោះ ពយកាក់ មានទំហំ ១១ ហិកតា

## ឃ-ធនធានជលផល

- ប្រភេទត្រី ( ត្រីបបែល ត្រីឆ្លាម ប្លាធូ ត្រីតុកកែ ត្រីថ្កោង ត្រីក្បក កុយតាំង អណ្តែងពុយ ការាវ បេកា ស្លង់ ត្រីគម ឪឈៀវ បិះឈៀវ ត្រីស ត្រីស្លឹកឬស្សី ត្រីឆ្កុក ត្រីក្បាលហែង ត្រីប៉ាកុង...... )
- ប្រភេទវារីសត្វ (អណ្តើក ពស់ ក្តាមថ្ម ក្តាមសេះ ខ្យង ផ្សោត បាលាំងកាស បង្គា មឹក មឹកដៃ បង្កង បង្កងប៉ាក គ្រុតគ្រែង ខ្យងភី ងាវ...... )
- ប្រភេទរុក្ខជាតិព្រៃលិចទឹក និងវារីរុក្ខជាតិ ( ផ្កាថ្ម សារ៉ាយ ពុលទឹក ស្មៅ ......)

# ៤.ការធ្វើនេសាទ

## ក-អ្នកនេសាទ

- អ្នកនេសាទជាសមាជិកសហគមន៍នេសាទមានចំនួន ១,៩២៦ នាក់ ស្រី ៩៦០ នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ នៅក្នុងសហគមន៍មានចំនួន ៣,០៨៥នាក់ ស្រី ១,៤៨០នាក់
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍មានចំនួន ៣០០នាក់ ស្រី ៣០ នាក់

## ខ-ឧបករណ៍នេសាទ

- ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ (ខែ.........ដល់ខែ.........) |
|---|---|---|---|---|
| មងបង្គា | ២២៦ គ្រួសារ | ១០០០ ផែ | ២២៦,០០០ ម៉ែត្រ | ខែ មករា ដល់ ខែ មិថុនា |
| សន្ទូចរនង | ២៥ គ្រួសារ | ៤៥០០ផ្លែ | ៧៥០០ ម៉ែត្រ | ខែ កក្កដា ដល់ ខែ សីហា |
| លបក្តាមសេះ | ១៥ គ្រួសារ | ៤៥០ លប | ២២៥០ ម៉ែត្រ | ខែ កញ្ញា ដល់ ខែធ្នូ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកកន្ទុយវែង | ២៨០ ទូក | ១តោន ទៅ ២តោន | ៦ សេះ ទៅ ១៥ សេះ |

- ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកនៅក្នុងតំបន់ ប៉ុន្តែមិនមែនជាសមាជិកសហគមន៍នេសាទៈ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង |
|---|---|---|---|
| មងក្តាម | ៦០គ្រួសារ | ៦,០០០លប | ៣០,០០០ ម៉ែត្រ |
| លបក្តាម | ៣០គ្រួសារ | ៦,០០០លប | ៦,០០០ ម៉ែត្រ |
| សន្ទូចរនង | ២០ គ្រួសារ | ១០,០០០ ផ្លែ | ១៥,០០០ ម៉ែត្រ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
| --- | --- | --- | --- |
| ទូកកន្ទុយវែង | ១០ ទូក | ១តោន ទៅ ២តោន | ១២ សេះ ទៅ ១៥ សេះ |
| កាណូត | ៥ ទូក | ២ តោន ទៅ ២,៥ តោន | ២២ សេះ ទៅ ៣២ សេះ |

- ឧបករណ៍នេសាទ និងទូក កាណូតរបស់អ្នកមិនមែនជាសមាជិកដែលមកពីក្រៅសហគមន៍នេសាទ:

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង |
| --- | --- | --- | --- |
| មងត្រី ស | ៣០ គ្រួសារ | ១២០ ផែ | ៣៦,០០០ ម៉ែត្រ |
| លប ក្តាម | ៥ គ្រួសារ | ១០០០លប | ៥,០០០ ម៉ែត្រ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
| --- | --- | --- | --- |
| កាណូត | ២ គ្រួសារ | ៣តោន | ២២ សេះ ទៅ ៣២ សេះ |

### គ-ប៉ាន់ប្រមាណ ផលនេសាទចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ (គិតជា គក) | | |
| --- | --- | --- | --- |
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| ត្រីគ្រប់មុខ | ៤០០ គក | ២០០គក | ៦០០គក |
| ក្តាម | ៣០ គក | ២០គក | ៥០គក |
| ខ្យងគ្រប់មុខ | ៤៥ គក | ១០គក | ៥៥គក |
| បង្គា | ៦០០គក | ១៥០គក | ៧៥០គក |
| បបែល | ៣០គក | ១២០គក | ១៥០កក |

## ៥.ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ក-ទស្សនៈវិស័យ

សហគមន៍នេសាទតំបន់ឆ្នេរសមុទ្រឃុំជ្រោយស្វាយ មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រង និងប្រើប្រាស់ ធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ-គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទទឹកប្រៃដែលបានលុប ឬ កន្លែងនេសាទគ្រួសារ ដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬ សហគមន៍ធ្វើនេសាទ កន្លែងនេសាទបម្រុងទំនាបលិចទឹកក្នុងរដូវដំឡើង និងព្រៃកោងកាង និងកន្លែងនេសាទតាមឆ្នេរ

- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និង ធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរ ប្រកបដោយសមធម៌
- ដើម្បីធ្វើឲ្យប្រសើឡើងនូវជីវភាពសមាជិកសហគមន៍នេសាទ តាមរយៈការអភិវឌ្ឍន៍ចំរុះដោយមានការចូលរួមពីសមាជិកសហគមន៍
- ដើម្បីអោយប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់ផ្ទាល់លើធនធានធម្មជាតិ។

## គ-ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### គ-១-ផែនការប្រើប្រាស់ឧបករណ៍នេសាទៈ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ គឺរៀបចំឡើងដោយគិតគូរអំពីប្រភេទ ដែននេសាទ ប្រភេទទំហំ ប្រវែង និងចំនួនឧបករណ៍នេសាទ ចំនួនអ្នកនេសាទ និងរដូវនេសាទ។ ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍ត្រូវបានរៀបចំឡើងដូចខាងក្រោមៈ

| ឈ្មោះ/ទីតាំង កន្លែងនេសាទ | ពេលវេលា ធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឲ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| សហគមន៍នេសាទឃុំជ្រោយស្វាយ | ៦ខែ | មងក្តាម | ៥០០ម៉ែត្រ | ៥ ផៃ | ខែ កញ្ញា ដល់ ខែធ្នូ |
| សហគមន៍នេសាទឃុំជ្រោយស្វាយ | ១០ខែ | លបក្តាម | ៧០០ម៉ែត្រ | ៣០០លប | ខែ កញ្ញា ដល់ ខែធ្នូ |
| សហគមន៍នេសាទឃុំជ្រោយស្វាយ | ៩ខែ | មងបង្គា | ៥០០ម៉ែត្រ | ៥ ផៃ | ខែ មករា ដល់ ខែ មិថុនា |

## គ-២-ផែនការកែលម្អដែននេសាទ

ផែនការកែលម្អដែននេសាទត្រូវបានរៀបចំឡើងដូចមានក្នុងតារាងខាងក្រោមៈ

| ឈ្មោះដែននេសាទ | ទំហំ | ទំហំដែលត្រូវកែលម្អ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| សហគមន៍នេសាទឃុំជ្រោយស្វាយ | ១៣,៤៨៣ហិកតា | ២ហិកតា | សង់ទីស្នាក់សហគមន៍ កញ្ចុះ សំរាប់ភ្ញៀវមកលេង | ខែ កុម្ភៈ ២០១៧ | ខែ មេសា ២០១៧ | |
| សហគមន៍នេសាទឃុំជ្រោយស្វាយ | ១៣,៤៨៣ហិកតា | ២០០០០ ម៉ែត្រ | សំអាតបរិស្ថានមាត់ឆ្នេរសមុទ្រ | ខែ វិច្ឆិកា ២០១៧ | ខែ ធ្នូ ២០១៧ | |

## គ-៣-ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស

ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស នឹងត្រូវរៀបចំឡើងដូចមាននៅក្នុងតារាងខាងក្រោមៈ

| ឈ្មោះដែននេសាទ | ទំហំ | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| សហគមន៍នេសាទឃុំជ្រោយស្វាយ | ៦២ ហិកតា | ដាក់ប្រអប់ជំរកត្រីសិប្បនិមិត្ត | ចេញល្បាតកុំអោយមានសកម្មភាពនេសាទ | ខែ មករា ២០១៧ | ខែ ធ្នូ ២០១៩ | |

## គ-៤-ផែនការគ្រប់គ្រងព្រៃលិចទឹក

ផែនការគ្រប់គ្រងព្រៃលិចទឹកត្រូវបានរៀបចំឡើង ដូចមាននៅក្នុងតារាងខាងក្រោមៈ

| ឈ្មោះ/ទីតាំង | ទំហំ | ប្រភេទកូនឈើដែលត្រូវដាំ និងការពារ | សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១-ដាំព្រៃលិចទឹក | ៥ហិកតា | កូនកោងកាង កូនស្មែរ | ដាំកូនឈើ | ខែ មិថុនា ២០១៧ | ខែ សីហា ២០១៧ | |

## គ-៥-ផែនការបង្កើនផលស្តុកក្នុងធម្មជាតិ

ត្រូវបានរៀបចំឡើង ដូចមាននៅក្នុងតារាងខាងក្រោមៈ

| ប្រភេទ | ចំនួន | ប្រភេទពូជក្តាម | បរិមាណកូនក្តាមពូជ | ខែ/ឆ្នាំ | |
|---|---|---|---|---|---|
| | | | | ចាប់ផ្តើម | ប្រមូលផល |
| បែរ | ១ | ក្តាមសេះ | មេក្តាម១ក្បាល មានកូនប្រហែល ៧០០០០ក្បាល (ប៉ាន់ស្មានកូនក្តាមរស់) | ខែធ្នូ | ខែមករា ដល់ខែ កក្កដា |

## គ-៦-ផែនការថវិកាទ្រទ្រង់សំរាប់អភិវឌ្ឍសហគមន៍

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូលសរុប | ផ្សេងៗ |
|---|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | ចុះប្រមូលថវិកាប្រចាំខែពីសមាជិក | ខែ មករា ២០១៧ | ខែ ធ្នូ ២០១៧ | ២,៥៨៦,០០០រៀល | |
| ការបំរើរសេវាកម្មទេសចរណ៍ | រៀបចំតំបន់អេកូទេសចរណ៍ | ខែ មករា ២០១៧ | ខែ ធ្នូ ២០១៧ | ១,០០០,០០០រៀល | |

## គ-៧-ផែនការផ្សេងៗទៀត

### ឃ- យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការអោយទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំដូចខាងក្រោមៈ

- បង្កើតគណៈកម្មការសម្រាប់អនុវត្ត តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តផែនការរួមមានៈ សមាជិក គណៈកម្មការសហគមន៍នេសាទ ចាស់ទុំ និងសមាជិកគណៈកម្មការនេសាទដែល មានបទពិសោធន៍ និងចំណេះដឹងល្អៗ ជាពិសេសអំពីបញ្ហានេសាទ
- ស្នើសុំជំនួយបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណា ដែលទាក់ទងនិងបច្ចេកទេសជលផលដូចជាៈ ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្សព្រៃលិច ទឹក កន្លែងអភិរក្សជីវចំរុះ ការស្តារព្រែក ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោង និងម្ចាស់ជំនួយដើម្បីទទួលបាន ការឧបត្ថម្ភគាំទ្រ និងថវិកាសម្រាប់ដំណើរការអនុវត្តផែនការ
- រៀបចំកម្មវិធីអនុវត្តផែនការតាមដំណាក់កាលនីមួយៗដោយជាក់លាក់
- ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិកា និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រង សហគមន៍នេសាទ
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ
- គៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ
- រៀបចំវិធានការចំពោះអ្នកនេសាទមកពីក្រៅសហគមន៍
- ពង្រឹងសម្ថភាពបច្ចេកទេស និងគ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ
- បញ្ចូលផែនការការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។

តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍នេសាទតំបន់ឆ្នេរជ្រោយស្វាយ រយៈពេល ៣ឆ្នាំ (២០១៧ដល់២០១៩)

| ប្រភេទផែនការ | សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| ១,ការចុះផ្សព្វផ្សាយ | ផ្សព្វផ្សាយពីច្បាប់ជលផល កុំអោយសមាជិកប្រើឧបករណ៍នេសាទខុសច្បាប់ | សមាជិក ប្រើប្រាស់ឧបករណ៍នេសាទស្របច្បាប់ | ២៤០ $ | ស្វែងរកថវិកាពីអង្គការផ្សេងៗ និងបដិភាគសហគមន៍ | ខែមីនា | ខែមិថុនា | |
| ២,ការកែលម្អតំបន់មាត់ឆ្នេរ | សំអាតបរិស្ថានមាត់សមុទ្រ | មាត់សមុទ្រឃុំជ្រោយស្វាយត្រូវបានសំអាតស្អាត ចំនួនប្រវែង ២០០០០ម៉ែត | ២០០ $ | ស្វែងរកថវិកាពីអង្គការផ្សេងៗ និងបដិភាគសហគមន៍ | ខែ វិច្ឆិកា ២០១៧ | ខែ ធ្នូ ២០១៧ | |
| | សង់ទីស្នាក់ការសហគមន៍ ធ្វើកញ្ចុះ សំរាប់ភ្ញៀវមកលេង | ទីស្នាក់ការត្រូវបានសាងសង់រួចក្នុងខែ កុម្ភៈ ២០១៧ | ៣០០០ $ | ស្វែងរកថវិកាពីអង្គការផ្សេងៗ និងបដិភាគសហគមន៍ | ខែ កុម្ភៈ ២០១៧ | ខែ មេសា ២០១៧ | |
| ៣,ការកំណត់និងរៀបចំតំបន់អភិរក្ស | ដាក់ប្រអប់ជំរកត្រីសប្បនិមិត្ត | ជំរកត្រីពងទំហំ ៤៣ ហិកតាបានអភិរក្ស | ១,៥០០$ | ស្វែងរកថវិកាពីអង្គការផ្សេងៗ | ខែ មករា ២០១៧ | ខែ ធ្នូ ២០១៩ | |
| ៤,ផែនការគ្រប់គ្រងព្រៃលិចទឹក | ដាំកូនឈើ កូនកោងកាង កូនស្មែរ | ដីចំនួន ៥ហិកតា និងបានដាំកូនកោងកាង | ៤៥០ $ | បដិភាគសហគមន៍ | ខែ មិថុនា ២០១៧ | ខែ សីហា ២០១៧ | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | ចំនួន ៥០០០០ ដើម | | | | | |
| ៥,បង្កើនផលទុកក្នុងធម្មជាតិ | បង្កើតធនាគារក្ដាមសេះ | ទទួលបានផលក្ដាមមានការកើនឡើង | មេក្ដាម១ក្បាលមានកូនប្រហែល ៧០០០០ក្បាល | បដិភាគសហគមន៍ | ខែមករា ២០១៧ | ខែធ្នូ ២០១៧ | |
| ៦,ផែនការរកប្រាក់ចំណូលសហគមន៍ | ការបំរើរសេវាកម្មទេសចរណ៍ | រៀបចំតំបន់អេកូទេសចរណ៍ក្នុងសហគមន៍ជ្រោយស្វាយបានចំនួន ១ កន្លែង | ២០០០$ | ស្វែងរកជំនួយពីអង្គការ | ខែ មករា ២០១៧ | ខែ ធ្នូ ២០១៧ | |
| ៧,ធ្វើការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍ | វគ្គបណ្ដុះបណ្ដាលភាពជាអ្នកដឹកនាំ | គណៈកម្មកាមានចំណេះដឹងក្នុងភាពជាអ្នកដឹកនាំ | ៧០០$ | ជំនួយពីអង្គការ | ខែ មីនា | ខែ មេសា | |

## តារាងកម្មវិធីការងារ

| សកម្មភាព | កាលបរិច្ឆេទ | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៧ | | | | | | | | | | | | ២០១៨ | | | ២០១៩ | | |
| | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | មករា | …… | ធ្នូ | មករា | …… | ធ្នូ |
| ១,ផ្សព្វផ្សាយពីច្បាប់ជលផល | | | √ | √ | √ | √ | | | | | | | | | | | | |
| ២,១ការកែលតំបន់មាត់ឆ្នេរ | | √ | √ | √ | | | | | | | | | | | | | | |
| ២,២ សំអាតបរិស្ថានមាត់សមុទ្រ | | | | | | | | | | | √ | √ | | | | | | |
| ៣,ការកំណត់និងរៀបចំតំបន់អភិរក្ស | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | | | | | | |
| ៤,ដាំកូនឈើ កូនកោងកាង កូនស្មៅ | | | | | √ | √ | √ | √ | | | | | | | | | | |
| ៥,បង្កើតធនាគារក្តាមសេះ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | | | | | | |
| ៦,ការបំរើសេវាកម្មទេសចរណ៍ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | √ | | | | | | |
| ៧,ធ្វើការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍ | | | √ | √ | | | | | | | | | | | | | | |

ជ្រោយស្វាយ ថ្ងៃទី20 ខែ12 ឆ្នាំ2016
ប្រធានគណៈកម្មការសហគមន៍នេសាទតំបន់ឆ្នេរសមុទ្រជ្រោយស្វាយ

លេខៈ ០៥៤/១៦ ន.ខ.ន
បានឃើញ និងបញ្ជូនមក
លោកនាយខណ្ឌរដ្ឋបាលជលផលកោះកុង
" ដើម្បីពិនិត្យ និងជួយសំរួលដោយអនុគ្រោះ"
..........,ថ្ងៃទី.....ខែ.....ឆ្នាំ២០១៦
នាយផ្នែករដ្ឋបាលជលផលបុទុមសាគរ

លេខៈ ៤២០/១៦ ម.គ.យ
បានឃើញ និងបញ្ជូនមក
លោកនាយផ្នែករដ្ឋបាលជលផលបុទុមសាគរ
" ដើម្បីពិនិត្យ និងជួយសំរួលដោយអនុគ្រោះ"
ជ្រោយស្វាយ,ថ្ងៃទី.....ខែ.....ឆ្នាំ២០១៦
មេឃុំជ្រោយស្វាយ

លេខៈ ៣២៨១ ស.ជ.ន
បានឃើញ និងឯកភាព
រាជធានីភ្នំពេញ,ថ្ងៃទី.....ខែ.....ឆ្នាំ២០១៧
**ឯឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជា**
**ប្រធានរដ្ឋបាលជលផល**

អ៊ុច ជាសាន

លេខៈ ០៦០ អ.ក.ផ
បានឃើញ និងបញ្ជូនមក
ឯឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធាន
រដ្ឋបាលជលផល
" ដើម្បីពិនិត្យ និងសម្រេចដោយអនុគ្រោះ"
ភ្នំពេញ.........,ថ្ងៃទី០១ខែ.....ឆ្នាំ២០១៧
លោកនាយអធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ

លេខៈ ០៥៧ ខ.ជ.ក.ក
បានឃើញ និងបញ្ជូនមក
លោកនាយអធិការដ្ឋានរដ្ឋបាលជលផលសមុទ្រ
" ដើម្បីពិនិត្យ និងជួយសំរួលដោយអនុគ្រោះ"
កោះកុង,ថ្ងៃទី.....ខែ.....ឆ្នាំ២០១៦
នាយខណ្ឌ រដ្ឋបាលជលផលកោះកុង